ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
លេខ : ០៥០ ដរសណ/ប្រក/ក.ក.ច

# ប្រកាស
# ស្តីពី
# បែបបទនិងនីតិវិធីនៃការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ដែលត្រូវបានសាងសង់រួចមុនថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៨៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៤ ន.ស.៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១០/០០៦ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការផ្តល់សិទ្ធិកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិដល់ជនបរទេស
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី


ទូរស័ព្ទ (855) 23 886 999 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ
- បានឃើញអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា១៦ និងមាត្រា១៧ នៃអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រង និងប្រើប្រាស់អគារសហកម្មសិទ្ធិ
- បានឃើញអនុក្រឹត្យលេខ១២១ អនក្រ.បក ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៩ និងមាត្រា១៣ នៃអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ
- បានឃើញអនុក្រឹត្យលេខ១២២ អនក្រ.បក ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៦ មាត្រា៧ និងមាត្រា១១ នៃអនុក្រឹត្យលេខ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញប្រកាសលេខ២៦២ ប្រក. ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការបង្កើត និងដាក់ឱ្យប្រើប្រាស់ឯកសារបម្រើឱ្យការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១._**

ប្រកាសនេះកំណត់អំពីបែបបទនិងនីតិវិធីនៃការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ក្នុងគោលបំណងដើម្បីធានាការពារសិទ្ធិកម្មសិទ្ធិស្របច្បាប់ របស់អ្នកកាន់កាប់ចំណែកឯកជននៃអគារសហកម្មសិទ្ធិ។

**ប្រការ២._**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះអគារសហកម្មសិទ្ធិទាំងអស់ដែលត្រូវបានសាងសង់រួចមុនថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧។

**ប្រការ៣._**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១- **ចំណែកឯកជន** សំដៅដល់ចំណែកនៃអគារសហកម្មសិទ្ធិដែលស្ថិតក្រោមការកាន់កាប់ ប្រើប្រាស់ និងចាត់ចែងជាឯកជនផ្តាច់មុខ។

២- **តំណាងស្របច្បាប់របស់នីតិបុគ្គល** សំដៅដល់ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន អគ្គនាយកក្រុមហ៊ុន នាយកក្រុមហ៊ុន ឬអភិបាលនៃសហគ្រាសឯកបុគ្គល ដែលមានគោត្តនាមនិងនាមត្រូវបានចែងនៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ឬភ្នាក់ងារតំណាងរបស់ក្រុមហ៊ុនសញ្ជាតិបរទេសដែលបានបង្កើតឡើងក្រោមច្បាប់នៃប្រទេសដទៃ ឬប្រធានឬនាយកប្រតិបត្តិដែលមានគោត្តនាមនិងនាមត្រូវបានចែងនៅក្នុងលក្ខន្តិកៈឬអនុស្សរណៈរបស់អង្គការឬសមាគម ឬអ្នកតំណាងអង្គការឬសមាគម ឬប្រធានឬអ្នកតំណាងគណបក្សនយោបាយ ឬបវរជនបុគ្គលដទៃទៀតដែលមានគោត្តនាមនិងនាមត្រូវបានចែងនៅក្នុងប្រកាសឬលិខិតបទដ្ឋានស្ដីពីការចុះបញ្ជីឬការទទួលស្គាល់នីតិបុគ្គលនោះ។

៣- **អគារសហកម្មសិទ្ធិ** សំដៅដល់អគារឬសំណង់ដែលមានកម្មសិទ្ធិករច្រើននាក់រស់នៅ។ អគារសហកម្មសិទ្ធិមានចំណែកខ្លះជាកម្មសិទ្ធិផ្ដាច់មុខរបស់សហកម្មសិទ្ធិករនីមួយៗហៅថា "ចំណែកឯកជន" និងមានចំណែកខ្លះជាលំហរួមសម្រាប់ការប្រើប្រាស់រួមរបស់សហកម្មសិទ្ធិករទាំងអស់ហៅថា "ចំណែករួម"។ ប្រភេទនៃអគារសហកម្មសិទ្ធិទាំងនោះ មានជាអាទិ៍ ភូមិគ្រឹះ ពាក់កណ្ដាលភូមិគ្រឹះ ផ្ទះល្វែងដែលមានច្រើនល្វែងនិងច្រើនជាន់ជាប់ៗគ្នា ខុនដូ ប្រភេទផ្ទះផ្សេងទៀតដែលមានរចនាសម្ព័ន្ធជាប់គ្នា។

## ជំពូកទី២
## បែបបទនៃការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ

**ប្រការ៤._**

សំណុំឯកសារស្នើសុំចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ មានដូចខាងក្រោម៖

| | | |
|---|---|---|
| ១- | ពាក្យស្នើសុំចុះបញ្ជី | ចំនួន១ច្បាប់ |
| ២- | ឯកសារបញ្ជាក់អត្តសញ្ញាណសហកម្មសិទ្ធិករម្នាក់ៗ(ថតចម្លង) | ចំនួន២ច្បាប់ |
| ៣- | ឯកសារបញ្ជាក់ការកាន់កាប់ស្របច្បាប់លើអចលនវត្ថុ(ថតចម្លង)ប្រសិនបើមាន | ចំនួន២ច្បាប់។ |

គំរូទម្រង់ពាក្យស្នើសុំចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ជាឧបសម្ព័ន្ធ១នៃប្រកាសនេះ។

**ប្រការ៥._**

ម្ចាស់សំណើត្រូវផ្ដិតស្នាមមេដៃស្ដាំឬចុះហត្ថលេខាដោយផ្ទាល់លើពាក្យស្នើសុំចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ។

ក្នុងករណីម្ចាស់សំណើជាសហគ្រាសឯកបុគ្គល ពាក្យស្នើសុំត្រូវមានស្នាមមេដៃស្ដាំឬហត្ថលេខា គោត្តនាមនិងនាមរបស់តំណាងស្របច្បាប់និងត្រារបស់សហគ្រាសនោះ។

ក្នុងករណីម្ចាស់សំណើជាក្រុមហ៊ុនសហកម្មសិទ្ធិឬក្រុមហ៊ុនមូលធន ពាក្យស្នើសុំត្រូវមានស្នាមមេដៃស្ដាំឬហត្ថលេខា គោត្តនាមនិងនាមរបស់តំណាងស្របច្បាប់ និងត្រារបស់សហគ្រាសនោះ និងត្រូវភ្ជាប់មកជាមួយនូវលិខិតប្រគល់សិទ្ធិរបស់ភាគហ៊ុននិកឬរបស់ក្រុមប្រឹក្សាភិបាលដូចមានចែងនៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុននោះ។

ក្នុងករណីម្ចាស់សំណើជានីតិបុគ្គលផ្សេងទៀត ពាក្យស្នើសុំត្រូវមានស្នាមមេដៃស្តាំឬហត្ថលេខា គោត្តនាមនិងនាមរបស់តំណាងស្របច្បាប់និងត្រារបស់នីតិបុគ្គលនោះ និងត្រូវភ្ជាប់មកជាមួយនូវលិខិតប្រគល់សិទ្ធិរបស់អង្គសម្រេចចិត្តនៃនីតិបុគ្គលនោះដូចមានចែងនៅក្នុងលក្ខន្តិកៈឬអនុស្សរណៈរបស់នីតិបុគ្គលនោះ។

គំរូទម្រង់លិខិតប្រគល់សិទ្ធិ ជាឧបសម្ព័ន្ធ២នៃប្រកាសនេះ។

**ប្រការ៦._**

រាល់សំណុំឯកសារស្នើសុំចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិត្រូវធ្វើជាភាសាខ្មែរ។

រាល់ឯកសារថតចម្លងមិនតម្រូវឱ្យធ្វើនីត្យានុកូលកម្មឡើយ។

## ជំពូកទី៣

## នីតិវិធីនៃការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ

**ប្រការ៧._**

បទប្បញ្ញត្តិស្តីពីនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធដូចមានចែងក្នុងអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដីនិងសៀវភៅគោលបញ្ជីដីធ្លី, អនុក្រឹត្យលេខ១២២ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៦ មាត្រា៧ និងមាត្រា១១ នៃអនុក្រឹត្យលេខ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដីនិងសៀវភៅគោលបញ្ជីដីធ្លី និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះនីតិវិធីនៃការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលត្រូវបានសាងសង់រួចមុនថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧។

ចំណែកឯកជនទាំងឡាយនៃអគារសហកម្មសិទ្ធិដែលត្រូវបានសាងសង់រួចមុនថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ និងដែលខកខានមិនបានចុះបញ្ជីតាមនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ អាចត្រូវបានចុះបញ្ជីបំពេញបន្ថែមតាមនីតិវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំដូចមានចែងក្នុងអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ និងអនុក្រឹត្យលេខ១២១ អនក្រ.បក ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៩និងមាត្រា១៣ នៃអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ។

**ប្រការ៨._**

ម្ចាស់ចំណែកឯកជននៃអគារសហកម្មសិទ្ធិ ត្រូវប្រគល់ច្បាប់ដើមនៃវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលើផ្ទះសម្បែងឬឯកសារដទៃទៀតដែលបញ្ជាក់ការកាន់កាប់ស្របច្បាប់លើអចលនវត្ថុប្រសិនបើមាន ជូនរដ្ឋបាលសុរិយោដីដើម្បីដូរយកវិញ្ញាបនបត្រសម្គាល់ម្ចាស់ចំណែកឯកជននៃអគារសហកម្មសិទ្ធិ។

ច្បាប់ដើមនៃវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលើផ្ទះសម្បែង ត្រូវបោះត្រាមោឃៈ និងរក្សាទុកនៅរដ្ឋបាលសុរិយោដី។ ច្បាប់ដើមនៃឯកសារដទៃទៀតដែលបញ្ជាក់ការកាន់កាប់ស្របច្បាប់លើអចលនវត្ថុត្រូវរក្សាទុកនៅរដ្ឋបាលសុរិយោដី។

## ជំពូកទី៤
## សេវាសុរិយោដី

**ប្រការ៩.—**

ការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ដូចមានកំណត់ក្នុងប្រកាសនេះ ត្រូវបង់កម្រៃសេវាសុរិយោដី។

តម្លៃសេវាសុរិយោដី ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ១០.—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១១.—**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១៤កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**សាយ សំអាល់**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី

 "ដើម្បីជូនជ្រាប"
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១១

 "ដើម្បីមុខការ"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ១នៃប្រកាសលេខ ____________ ចុះថ្ងៃទី ________ ខែកក្កដា ឆ្នាំ២០២៤ ស្តីពីបែបបទនិងនីតិវិធីនៃការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលត្រូវបានសាងសង់រួចមុនថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧

***គំរូទម្រង់ពាក្យស្នើសុំចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ***

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យស្នើសុំចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ____________ ភេទ ______ អាយុ ______ ឆ្នាំ សញ្ជាតិ ________
ប្រពន្ធ-ប្តីឈ្មោះ____________ មានទីលំនៅបច្ចុប្បន្ន នៅផ្ទះលេខ______ ផ្លូវលេខ__________ ភូមិ __________ ឃុំ/សង្កាត់__________ ក្រុង/ស្រុក/ខណ្ឌ__________ រាជធានី/ខេត្ត__________។

**សូមគោរពជូន**

**លោក/លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត**

**តាមរយៈ៖** លោក/លោកស្រីប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃរដ្ឋបាលក្រុង ស្រុកខណ្ឌ ______________________________

**កម្មវត្ថុ៖** សំណើសុំចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ

**ឯកសារភ្ជាប់៖** -ឯកសារបញ្ជាក់អត្តសញ្ញាណសហកម្មសិទ្ធិករ
-ឯកសារបញ្ជាក់ការកាន់កាប់ស្របច្បាប់លើអចលនវត្ថុ (ប្រសិនបើមាន)
-ឯកសារផ្សេងទៀត (ប្រសិនបើមាន) ______________________

តាមកម្មវត្ថុដូចមានចែងខាងលើ ខ្ញុំបាទ/នាងខ្ញុំគោរពស្នើសុំចុះបញ្ជីចំណែកឯកជនរបស់ខ្ញុំបាទ/នាងខ្ញុំដែលស្ថិតនៅជាន់ទី____នៃអគារសហកម្មសិទ្ធិឈ្មោះ______________(ប្រសិនបើមាន) នៅផ្លូវលេខ ភូមិ__________ ឃុំ/សង្កាត់______________ ក្រុង/ស្រុក/ខណ្ឌ__________ រាជធានី/ខេត្ត__________ មានទំហំប្រមាណ________(ម²) ដែលបានកាន់កាប់និងប្រើប្រាស់ចាប់ពីឆ្នាំ________ មកដល់បច្ចុប្បន្ន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធាន មេត្តាពិនិត្យនិងសម្រេចដោយសេចក្តីអនុគ្រោះ។

______________ ថ្ងៃទី ____ ខែ ________ ឆ្នាំ២០___

ស្នាមមេដៃ

លេខ ______________

បានឃើញ និងបញ្ជូនមក
លោក/លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី
ដើម្បីពិនិត្យនិងសម្រេចតាមការគួរ។

______________ ថ្ងៃទី ____ ខែ ________ ឆ្នាំ២០________

**ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល**

ឧបសម្ព័ន្ធ២នៃប្រកាសលេខ ______________ ចុះថ្ងៃទី ______ ខែកក្កដា ឆ្នាំ២០២៤ ស្តីពីបែបបទនិងនីតិវិធីនៃការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិដែលត្រូវបានសាងសង់រួចមុនថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧

***គំរូទម្រង់លិខិតប្រគល់សិទ្ធិ***

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

| រូបសញ្ញានិងនាមករណ៍របស់នីតិបុគ្គល |
|---|

## លិខិតប្រគល់សិទ្ធិ

**យោង៖** លក្ខន្តិកៈឬអនុស្សរណៈរបស់ ________________________________________

យើងខ្ញុំជា ______________________________________________________ រួមមាន៖

១- លោក _________ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ________ ចុះថ្ងៃទី ____ ខែ ___ ឆ្នាំ២០_

២- លោកស្រី ______ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ________ ចុះថ្ងៃទី ____ ខែ ___ ឆ្នាំ២០_

៣- ______________________________________________________________

**សូមប្រគល់សិទ្ធិជូន**

លោក/លោកស្រី ________________ ភេទ ______ អាយុ ______ ឆ្នាំ សញ្ជាតិ ________
មានទីលំនៅបច្ចុប្បន្ន នៅផ្ទះលេខ __________ ផ្លូវលេខ _________ ភូមិ ____ ឃុំ/សង្កាត់ __________
ក្រុង/ស្រុក/ខណ្ឌ ______ រាជធានី/ខេត្ត _______

**ធ្វើជាតំណាងរបស់** ____________________________

ដោយមានសិទ្ធិពេញបរិបូរណ៍និងពេញសមត្ថភាពតាមផ្លូវច្បាប់ក្នុងការធ្វើជាតំណាងឱ្យ ___________ ក្នុងការផ្តិតស្នាមមេដៃឬចុះហត្ថលេខា និងបោះត្រា លើពាក្យស្នើសុំនិងឯកសារផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងការស្នើសុំចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ ស្ថិតនៅជាន់ទី ________ នៃអគារសហកម្មសិទ្ធិឈ្មោះ _________________ (ប្រសិនបើមាន) នៅផ្លូវលេខ ____ ភូមិ ________ ឃុំ/សង្កាត់ _______________ ______ ក្រុង/ស្រុក/ខណ្ឌ ___________ រាជធានី/ខេត្ត ____________ មានទំហំប្រមាណ ________ (ម$^2$) ដែលបានកាន់កាប់ប្រើប្រាស់ចាប់ពីឆ្នាំ __________ មកដល់បច្ចុប្បន្ន តាមបែបបទនិងនីតិវិធីជាធរមាន។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម អាជ្ញាធរនិងមន្ត្រីមានសមត្ថកិច្ច ទទួលស្គាល់និងជួយសម្រួលតាមការកំណត់ច្បាប់។

ថ្ងៃ __________ ខែ _____ ឆ្នាំ __________ ឆស័ក ព.ស.២៥៦_

ធ្វើនៅ __________ ថ្ងៃទី ______ ខែ ______ ឆ្នាំ ២០២_

ស្នាមមេដៃស្តាំរបស់អ្នកទទួលសិទ្ធិ ត្រា ស្នាមមេដៃអ្នកប្រគល់សិទ្ធិ

គោត្តនាមនិងនាម គោត្តនាមនិងនាម គោត្តនាមនិងនាម

បានឃើញ និងបញ្ជាក់ថា

ភាគីទាំងពីរមានសិទ្ធិប្រគល់និងទទួលសិទ្ធិ និងពិតជាបានផ្តិតស្នាមមេដៃនិងបោះត្រា

ចំពោះមុខសារការីប្រាកដមែន

______________________________

សារការី